# ជូនចំពោះប្រិយមិត្ត

ពីមុនអ្នកកើតមក អ្នកបានរស់នៅជាមួយព្រះបិតាមាតាសួគ៌ារបស់អ្នក ។ ព្រះវរបិតាសួគ៌ បានបង្កើតផែនការមួយសម្រាប់យើងគ្រប់គ្នាឲ្យមកកាន់ផែនដីនេះដើម្បីរៀនសូត្រ និង រីកចម្រើន ។ នេះគឺជាផែនការនៃសុភមង្គល ។ ព្រះយេស៊ូវគ្រីស្ទបានបង្ហាញផ្លូវដល់យើង ពេលទ្រង់បានយាងមកកាន់ផែនដី ។ ពេលអ្នកជ្រើសរើសធ្វើតាមទ្រង់ នោះអ្នកកំពុង ជ្រើសរើសធ្វើតាមផែនការរបស់ព្រះវរបិតាសួគ៌ ។ អ្នកកំពុងរីកចម្រើនប្រែក្លាយដូចជា ព្រះអង្គសង្គ្រោះ !

សូមបើកទៅ ទំព័រ ២៦ ដើម្បីរៀនបន្ថែមទៀតអំពីផែនការនៃសុភមង្គល ។ បន្ទាប់មក លេងល្បែងកម្សាន្តនៅលើ ទំព័រ ១៦ ។

ដោយក្ដីស្រឡាញ់

ទស្សនាវដ្ដី *ប្រិយមិត្ត*




### កន្លែងដែលយើងអានទស្សនាវដ្ដី *ប្រិយមិត្ត*

ឌេនហ្សេល ប៊ី និង អេលបា អ៊ី អាយុ ៨ និង ៩ឆ្នាំ អានទស្សនាវដ្ដី *ប្រិយមិត្ត*ជាភាសាអង់គ្លេសនៅផ្ទះ និងនៅព្រះវិហារនៅក្នុង ដាអេសសាឡឹម តង់សានី ។



### យើងចូលចិត្តមើលព្រះវិហារបរិសុទ្ធ

អ័ប្រាហាំ ហ្វឺមែនដូ និង អេណុក ធី អាយុ ៧, ១០ និង ៥ឆ្នាំ បានទៅលេង ព្រះវិហារបរិសុទ្ធ ហ្គូដាឡាយ៉ារ៉ា មិុកស៊ីកូជាមួយនឹងឪពុកម្ដាយរបស់ពួកគេ ។



### កូនចៀមរបស់ព្រះយេស៊ូវ

ខ្ញុំរីករាយនឹងសកម្មភាពផ្លុំកូនចៀមឲ្យទៅរកព្រះយេស៊ូវ ដកស្រង់មកពីគំនិតនៅក្នុង *ចូរមកតាមខ្ញុំ* ( ខែកញ្ញា ឆ្នាំ២០២០ ) ។

អារី អេស អាយុ ៤ ឆ្នាំ រដ្ឋតិចសាស ស.រ.អា.